ហេដ្ឋារចនាសម្ព័ន្ធផ្លូវគមនាគមន៍មានស្រាប់ក្នុងតំបន់គំរោងគឺ ផ្លូវលេខ ៣៨ (មើលផែនទីលេខ១ ស្ថិតនៅខាងស្តាំដៃ) ក្រុមហ៊ុននឹងស្តារឡើងវិញផ្លូវលេខ៣៨នេះ និងសាងសង់បន្ថែមបន្តរហូតដល់ទំនប់ទី១ ដែលមានប្រវែង ៨៧០០ម ។ ផ្លូវនេះធ្វើអំពីបេតុងដែក (Reinforcement Concrete) ដែលមានទទឹងខ្នងលើ ៦ម និង កំរាស់ ២០ ស.ម ។

ក្រុមហ៊ុននឹងសាងសង់ ផ្លូវម្ខាងទៀតខាងឆ្វេងដៃ នៃព្រែកទឹកឈូមានប្រវែង ៣៨០០ម (មើលផែនទីលេខ៣ និងលេខ៤) ផ្លូវនេះនឹង ធ្វើអំពីបេតុងដែក (Reinforcemen Concrete) ដែលមានទទឹងខ្នងលើ ៦ម ដូចគ្នា ។ បន្ថែមពីលើនេះ ភ្ជាប់ពីផ្លូវបេតុងនេះ ក្រុមហ៊ុនសាងសង់ផ្លូវលំក្រាលគ្រួសក្រហម/ល្បាយថ្ម ប្រវែង ១៥៤៣០ម ទទឹងខ្នងលើ ៨ ម ដល់ផ្លូវ ជាតិលេខ៣ (ក្នុងនោះ ស្តារផ្លូវចាស់ ប្រវែង ២៦៥០ ម) ។ ដើម្បីជៀសវាង ការខូចផ្លូវជាតិលេខ៣ ដោយសារ ការដឹកថ្ម ពីការដ្ឋានយកថ្ម នៅជុំបមាន់ព្រៃ ភូមិទ្វារថ្មី ឃុំព្រៃថ្នង ស្រុកទឹកឈូ ក្រុមហ៊ុនបានសាងសង់ ផ្លូវគ្រួសក្រហម/ល្បាយថ្ម បណ្តោះអាសន្នអមតាមផ្លូវជាតិនេះ ខាងឆ្វេងដៃ(តាមទិសដៅកំពត-ភ្នំពេញ) ប្រវែង ១៣៨៣០ មទទឹងខ្នងលើ ៤ ម ហើយភ្ជាប់ពីផ្លូវនេះ ត្រង់ផ្លូវបត់លោកយាយ ម៉ៅ ដល់ការដ្ឋានយកថ្ម ក្រុមហ៊ុនបានស្តារផ្លូវលំចាស់ ប្រវែង ៤៧៥០ម ទទឹងខ្នងលើ ៨ ម ផងដែរ ។ សរុបនៃ ការសាងសង់ផ្លូវ ចេញ-ចូល របស់គំរោងនេះ មានប្រវែងសរុប ៤១,៧៦ គម. (មើលតារាង១ខាងក្រោម) ។

ក្រុមហ៊ុនសាងសង់ស្ពាន៤កន្លែង ដែលមាន២កន្លែងកាត់ស្ទឹងកំចាយ គឺមួយធ្វើអំពីបេតុងបណ្តោះអាសន្ន (ទល់មុខអគារថាមពលទី១), ស្ពានបេតុងទី២ នៅខាងក្រោមទំនប់ទី១ ។ ចំណែកឯស្ពានពីរទៀតគឺមួយធ្វើពីបេតុងកាត់អូរបីឬអូរតាជា និងមួយទៀតធ្វើអំពីដែក កាត់ស្ទឹងកែវ ដើម្បីភ្ជាប់ ចរាចរផ្លូវសងខាងស្ទឹងទាំងពីរ ផងដែរ (មើលផែនទីលេខ៣ និងលេខ៤) ។

**តារាង៥ : សរុបចំនួនសាងសង់ប្រភេទផ្លូវរបស់គំរោង**

| No | Road Type | Length (km) |
|---|---|---|
| 1 | Concrete Road (W = 6m) | 12.50 |
| 2 | New Laterite Road (W = 8m) | 8.03 |
| 3 | New Temporary Laterite Road (W = 4m) | 13.83 |
| 4 | Rehabilitation Laterite Road (W = 8m) | 7.40 |
| | Total | 41.76 |

### ៤.៥.៤ អាងស្តុកទឹកទី១ ទំនប់ RCCD និងប្រព័ន្ធសំណង់សិល្បៈការរបស់វា (Reservoir No. 1, RCC Dam 1 and Associated Hydraulic Structure)

ជាគោលការណ៍នៃសំណង់វារីអគ្គិសនីគឺ ធ្វើអាងស្តុកទឹកពីរកន្លែងគឺ : ទំនប់ទប់កាត់ស្ទឹងកំចាយទី ១ (ព្រែកទឹកឈូ) ស្ថិតនៅខាងលើដែលហៅថា ទំនប់ទី១ឬទំនប់អាងទី១ RCCD (Roller Completed Concrete Dam) និងទំនប់ទី២ ឬទំនប់អាងទី២ ដែលស្ថិត នៅចំងាយប្រហែល ៣០០ម ពីរមណីយដ្ឋានទឹកឈូសព្វថ្ងៃគិតមកដល់ស្ពានយោល (មើលផែនទីលេខ១ និងលេខ៣) ។ អាងទឹកទី ១ នេះមានចំណុះ ៦៨១៣ លានម$^3$ មានផ្ទៃលើ (នៅនីវ៉ូ១៥១ម) ១៩,៩ គ.ម$^2$ (តារាង

៥.៣.៦ នៅក្នុង Technical Proposal Volume 1) ចំពោះផ្ទៃដីដែលសិក្សាក្នុងអាងនេះ ដោយយកមកគណនា គឺប្រមាណជា ២០ គ.ម ហើយទំនប់ ទាំងនេះមានបំពាក់ទៅ ដោយសំណង់សិល្បៈការជាច្រើន ដូចជា :

**៤.៥.៤.១ ទំនប់ទី១ (ទំនប់អាងស្តុកទឹកទី១ (RCC Dam))**

ទំនប់នេះធ្វើអំពីបេតុង និងបេតុងដែក មានកំពស់រហូតដល់១១២ម (បើធៀបពីនីវ៉ូបាតស្ទឹង៤១ម ដល់នីវ៉ូខ្នងទំនប់ ១៥៣ម) វាមានប្រវែងសរុប៥៦៨ ម (មើលផែនទីលេខ ២B និង DWG No: GZB-PL-H-01, GZB-PL-H-02) ហើយទំនប់ RCCD នេះមានសំណង់សិល្បៈការដូចតទៅ :

១- <u>**សំណង់ពង្វៀងចរន្តទឹក**</u> <u>(Diversion Conduit)</u>: សំណង់នេះនឹងធ្វើមុនទំនប់ RCCD ហើយមានលក្ខណៈជាសំណង់បណ្តោះអាសន្ន ។ សំណង់នេះធ្វើដើម្បីពង្វៀងទឹកនៅពេលធ្វើទំនប់អាងស្តុកទឹកទី១ ហើយនឹងត្រូវបិទទាំងស្រុងវិញនៅពេលដំណើរការវារីអគ្គិសនី ។ សំណង់នេះមានបំពង់បង្ហូរទឹកបេតុងដែលមានកំពស់១០ ម. និងទទឹង ៨ម. រាងជាអក្សរ D ប្រវែង ១៣០ម. និងកំរាស់ ០,៥ម ហើយបាត កន្លែងច្រកទឹកចូលខាងលើគ្រោងតំឡើងនូវកំរិតកំពស់ EL : ៤៥ម និងច្រកទឹកចេញខាងក្រោមបាតវាគ្រោងដាក់ EL : ៤៣ម ។ សំណង់ពង្វៀងចរន្តទឹកនេះមាន ប្រឡាយខាងលើ និងប្រឡាយខាងក្រោមប្រវែងសរុប ១៥០ម ។ នៅច្រកទឹកចូលខាងលើមានបំពាក់ទ្វារទឹកដើម្បីលៃតំរូវធារទឹកនៅពេល ដែលចាំបាច់ ។

២- <u>**ទំនប់ធ្វើពីបេតុង**</u> <u>(Non-Overflow RCC Dam)</u> : ទំនប់នេះធ្វើអំពីបេតុងដែលមានខ្នងលើ ៦ម នីវ៉ូខ្នងលើមានកំរិតកំពស់ EL : ១៥៣ម ប្រវែងសរុប ៥៦៨ម ទំនប់នេះសង់នៅខាងឆ្វេង និងខាងស្តាំដៃនៃ RCC Dam (មើល DWG No: GZB-PL-H-01, GZB-PL-H-02) ។

៣- <u>**បំពង់ទូនែលនាំទឹកទៅអគារថាមពលទី ១**</u> <u>(Diversion Tunnel)</u> : បំពង់នេះមានចែកចេញជាពីរចំណែកគឺ (មើលផែនទីលេខ៣ និង DWG No. KHP-TB-C-Plan-001):

- បំពង់បេតុងសម្ពាធខ្សោយ (Low Pressure Tunnel) មានមុខកាត់រាងជារង្វង់អង្កត់ផ្ចិតក្នុង ៧,៥ម. កំរាស់ ០,៥ម ប្រវែងសរុបរបស់បំពង់នេះមាន ១៦៩៧,៦ម. អ័ក្សបំពង់ខាងលើតំឡើងនៅកំរិតកំពស់ EL:១១៥ម. អ័ក្សបំពង់ ខាងក្រោមតំឡើងនៅកំរិតកំពស់ EL : ៩៨ម. ។ បំពង់នេះមានសមត្ថភាពអាចបង្ហូរទឹកចេញបាន ៥៥ម$^{៣}$/វិនាទី ។ នៅចុងបំពង់នេះមានអាងខ្វាលបេតុង ដែលតភ្ជាប់បំពង់នេះទៅនឹងបំពង់ដែកសម្ពាធខ្លាំង ។ អាងនេះមានមុខកាត់រាងជារង្វង់ ដែលមានអង្កត់ផ្ចិតក្នុង ១៥.៦ម កំពស់ ៩១ម. កំរាស់បេតុង ១ម ទៅ ១,៥០ម ។ នៅខាងមុខបំពង់នេះមានសំណង់យកទឹកចូល (Intake Structure) សំរាប់នាំទឹកចូលទៅតាមបំពង់នេះកាត់តាមអាងខ្វាល និងបំពង់ដែកសម្ពាធខ្ពស់រួចទៅអូសទួរប៊ីន កំលាំង ៦០ MW x 3 = 180 MW ។
- បំពង់ដែកសម្ពាធខ្ពស់ (High Pressure Tunnel) បំពង់នេះតភ្ជាប់ចេញពីអាងខ្វាលទៅអគារផលិតថាមពលទី១ ដែលមានអង្កត់ផ្ចិតក្នុង ៦,២ម ធ្វើអំពីដែក Q345-C ។ ប្រវែងសរុបបំពង់ដែក នេះមាន ២៧០ម. ។ បំពង់ដែកនេះមានតំណររាងY បែកជាបីចូលទៅទួរប៊ីននីមួយៗដែលមានអង្កត់ផ្ចិត ២,៨ ម ។

៤- <u>**ទំនប់បង្ហៀរ**</u> <u>(Spillway)</u>: ទំនប់បង្ហៀរនេះមានប្រវែង ៧៨ ម ដែលមាននីវ៉ូខ្នងលើ ១៣៥ ម (មើល DWG No: GZB-PL-H-01, GZB-PL-H-02, GZB-PL-H-03) ។ ជាទូទៅការគណនាគ្រោងធ្វើទំនប់បង្ហៀរគឺគិតតាមប្រូបាប៊ីលីតេរយៈពេលទឹកជំនន់ ១:៥០០ ឆ្នាំ យ៉ាងតិចតាមការប៉ាន់ប្រមាណរបស់ក្រុមហ៊ុនធារទឹកជំនន់ដែលខ្លាំងជាងគេ ( Probable Maximum Flood) ក្នុងរយៈពេល ១០០០ឆ្នាំនោះគឺ ១០៧០០ម$^{៣}$/វិនាទី ។ ទំនប់បង្ហៀរនេះអាចមានសមត្ថភាពរំដោះទឹកជំនន់ បានជាអតិប្បរមាបាន ៨៣០៩ ម$^{៣}$/វិនាទី រីឯទឹកមួយចំនួន

ទៀតត្រូវបង្ហូរចេញតាមបំពង់របស់ទួលប៊ីននៃ អគារថាមពល ទី១ និងទី៣ ។ ពោលគឺទំនប់បង្វៀរនេះធ្វើឡើង ដើម្បីធានាកុំឱ្យជន់លិចតំបន់ខាងលើទំនប់ RCCD និងកុំឱ្យ គំរាមកំហែងដល់ហេដ្ឋារចនាសម្ព័ន្ធទំនប់វារីអគ្គិសនី ដទៃទៀត។ ទំនប់នេះ នឹងលៃតំរូវកំពស់ទឹកក្នុង អាងឱ្យនៅ ត្រឹមកំរិតកំពស់ត្រឹម (នីវ៉ូ) EL:១៥០ម ។ នៅលើ ទំនប់បង្វៀរនេះ មានតំឡើងទ្វារទឹក រាងកោង (Arc)ចំនួន ៥ ដែលប្រលោះទ្វារទឹកនិមួយៗមានកំពស់១៥ ម. និងទទឹង ១២ម. ។

#### ៤.៥.៤.២ អគារថាមពលទី ១ (Power House 1(PH1))

អគារថាមពលទី ១ (PH1) សាងសង់នៅក្រោមទំនប់ RCCD (ទីតាំងសូមពិនិត្យមើលជំពូកទី ៤ ចំណុច ៤.៣ ផែនទីលេខ៣ និង DWG No: KCF-H1-24) នៅអគារ PH1 នេះមានតំឡើងទួរប៊ីន ៣ ដែលទួរប៊ីននិមួយៗអាចផលិត ថាមពលអគ្គិសនីបាន ៦0MW (៦0MWx៣) ថាមពលអគ្គិសនីសរុបដែលអគារនេះអាចផលិតបានគឺ១៨0MW។ នៅរដូវវស្សា មានទឹកគ្រប់គ្រាន់អគារនេះ នឹងផលិតថាមពលអគ្គិសនី ២៤ ម៉ោងក្នុង១ថ្ងៃ ចំណែកឯនៅរដូវប្រាំងពេលដែលខ្វះទឹក អគារនេះធ្វើ ការផលិតតែ 0៤ ម៉ោង ប៉ុណ្ណោះក្នុង១ថ្ងៃ។

#### ៤.៥.៤.៣ អគារថាមពលទី ៣ (Power House 3 (PH3))

អគារថាមពលទី ៣ សាងសង់នៅខាងក្រោមជាប់ទំនប់ RCCD (ទីតាំងសូមពិនិត្យមើលជំពូកទី ៤ ចំណុច ៤.៣ ផែនទីលេខ ៣ និង DWG No: GZB-PL-H-02, GZB-PL-H-05) នៅអគារ PH3 នេះមានតំឡើងទួរប៊ីន ០១ ដែលអាច ផលិតថាមពលអគ្គិសនីបាន ៤ MW ។ នៅអគារនេះក៏មានតំឡើងបំពង់ដែកសំពាធខ្ពស់ (Penstock) ដែលមានអង្កត់ផ្ចិត ១,២ ម. និងប្រវែង ៥៨ ម. ។

#### ៤.៥.៤.៤ ទំនប់បណ្តោះអាសន្នខាងលើ (Upstream Cofferdam)

ទំនប់នេះនឹងសាងសង់នៅខាងលើទំនប់ RCCD ជាលក្ខណៈបណ្តោះអាសន្ន ធ្វើអំពីដី និង ថ្ម (ទីតាំងសូមពិនិត្យមើល ជំពូកទី ៤ ចំណុច ៤.៣ ផែនទីលេខ៣ និង DWG No: GZB-PL-H-01) ហើយវាមានតួនាទីការពារទឹកចូលនៅពេល ដែលគេសង់ទំនប់ RCCD ទំនប់នេះ មាននីវ៉ូខ្នងលើ ៥៣ម. និងទទឹងខ្នងលើ ៩ម. ប្រវែង ៨៨ម. កំពស់ ១០ម. ។ ទំនប់ នេះពេលគេសាងសង់ទំនប់ធំ RCCD រួច គេទំលាយវាចោល។

#### ៤.៥.៤.៥ ទំនប់ បណ្តោះអាសន្នខាងក្រោម (Downstream Cofferdam)

ទំនប់នេះនឹងសាងសង់នៅខាងក្រោមទំនប់ RCCD (ទីតាំងសូមពិនិត្យមើលជំពូកទី ៤ ចំណុច ៤.៣ ផែនទីលេខ៣ និង DWG No: GZB-PL-H-01) ហើយវាមានតួនាទីដូចទំនប់ខាងលើដែរគឺការពារទឹកចូលទៅកន្លែងសាងសង់ទំនប់ធំ RCCD ទំនប់នេះមាននីវ៉ូខ្នងលើ ៥០ម. និង ទទឹងខ្នងលើ ១២ម. ប្រវែង ៩០ម. កំពស់ ១០ម. ។ ទំនប់នេះពេលគេសាងសង់ទំនប់ធំ RCCD រួច គេទំលាយវាចោលវិញ។

### ៤.៥.៥ អាងស្តុកទឹកទី២ ទំនប់ និងប្រព័ន្ធសំណង់សិល្បៈការរបស់វា

(Reservoir No. 2, RCC Dam 2 and Associated Hydraulic Structure)

ទំនប់ទី ២ នេះ ជាប្រភេទ RCCD ដូចទំនប់ទី១ដែរ ធ្វើអំពីបេតុង ស្ថិតនៅខាងក្រោមខ្សែទឹកចំងាយប្រហែល ៣០០ម ពីរមណីយដ្ឋានទឹកឈូសព្វថ្ងៃ គិតមកដល់ ស្ពានយោលចាស់ (មើលផែនទីលេខ៣) ។ អាងនេះមានចំណុះទឹក ៨០០០ម$^{៣}$ មាន ផ្ទៃលើ (នីវ៉ូ២៥ម)គឺ ៣០ហ.ត ហើយទៅថ្ងៃអនាគតគេអាចយកទឹកទាំងសងខាងប្រាំងចេញពីអាងនេះដើម្បីទៅស្រោចស្រព កសិកម្ម និងផ្គត់ផ្គង់ទឹកដល់ទីក្រុងកំពត ។ ទំនប់នេះមានបំពាក់ទៅដោយសំណង់សិល្បៈការជាច្រើន ដូចជា :

#### ៤.៥.៥.១ ទំនប់ទី២ (ទំនប់អាងស្តុកទឹកទី២)(Concrete Auxiliary Dam)

ទំនប់នេះធ្វើអំពីបេតុង និងបេតុងដែក មានកំពស់រហូតដល់ ២១,៧ម (បើធៀបពីនីវ៉ូបាតស្ទឹង ៩,៣ម ដល់នីវ៉ូខ្នងទំនប់ ៣១ម) (មើលផែនទីលេខ៣ និង DWG No: KHP-TB-C-Plan-001) ហើយទំនប់ទី២នេះមានប្រវែងសរុប ៤៥៧ ម. ក្នុងនោះមានទំនប់បង្ហៀរ ១៩៧ ហើយមានសំណង់សិល្បៈ ការដូចតទៅ :

១- **ទំនប់ធ្វើពីបេតុង** (Non-Overflow Dam) : ទំនប់នេះធ្វើអំពីបេតុងដែលមានទទឹងខ្នងលើ ៣ម នីវ៉ូខ្នងលើមានការិតកំពស់ EL : ៣១ម ប្រវែងសរុប ២៦០ម ទំនប់នេះសង់នៅខាងឆ្វេង និងខាងស្តាំដៃនៃទំនប់បង្ហៀរ ។

២- **ទំនប់បង្ហៀរ** (Re-regulation Weir) : ទំនប់បង្ហៀរនេះធ្វើអំពីបេតុងដែក ដែលមុខកាត់មានរាងពាក់កណ្តាលអក្សរ S (Ogee Crest Cross Section) ដែលខាងក្រោមមានថ្នាក់ដូចកាំជណ្តើរដំរាប់ឱ្យទឹកបំបែកប៉ះនិងខ្យល់ធ្វើឱ្យកើតឡើងវិញនូវអុកស៊ីសែនរលាយក្នុងទឹកដើម្បីបន្ថយការប៉ះពាល់ដល់ជីវសាស្ត្ររស់នៅក្នុងទឹក ហើយវាមានប្រវែង ១៩៧ម នីវ៉ូខ្នងលើ ២៥ម ។_ទំនប់បង្ហៀរនេះមានលទ្ធភាពអាចដោះទឹកបានដែលយោងទៅតាមកំពស់នីវ៉ូទឹកក្នុងអាងទី ២ (មើលតារាង និង ក្រាហ្វិកខាងក្រោម) ។ (ទិន្នន័យបានពីក្រុមហ៊ុន)

| H (m) | 12.5 | 13 | 13.5 | 14 | 14.5 | 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 | 25 | 26 | 27 | 28 | 29 | 30 | 31 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| Q ($m^3/s$) | 3.7 | 19.5 | 45.5 | 81.5 | 123 | 177 | 350 | 573 | 848 | 1176 | 1556 | 1981 | 2227 | 2789 | 3473 | 4248 | 5120 | 6092 | 7170 | 8356 | 9656 | 11073 |




៣- **សំណង់បញ្ចេញទឹក** (Releasing Conduit) : សំណង់នេះមានមុខងារដូចតទៅ:

- ជំនួយបង្ហូរដោះទឹកជំនន់ និងលៃតំរូវនីវ៉ូទឹកខាងក្នុងអាង EL : ២៥ម ។
- រក្សាទឹកឱ្យគ្រប់គ្រាន់សំរាប់តំបន់ខាងក្រោមអាងគឺ នឹងបង្ហូរទឹកចេញអតិបរមា ៥ម³/វិនាទី នៅរដូវ ប្រាំង ។
- បង្ហូរទឹកឱ្យចេញអស់ពីអាងនៅពេលមានបញ្ហាកើតឡើងដោយចៃដន្យ ។ បាតសំណង់នេះនឹងសាងសង់នៅនីវ៉ូ EL: ២០ម ដែលមានប្រឡាយដែលមានមុខ ៧,៥ ម. និងប្រវែង ១៧០ម. ដែលនៅខាងមុខសំណង់នេះបំពាក់ដោយទ្វារទឹក ។

### ៩.៥.៥.២ អគារថាមពលទី ២ (Power House No.2 (PH2))

អគារថាមពលទី ២ (PH2) សាងសង់នៅខាងក្រោមជាប់ទំនប់ទី២នេះតែម្តង (ទីតាំងសូមពិនិត្យមើលជំពូកទី ៤ ចំណុច ៤.៣ ផែនទីលេខ៣ និង DWG No: KCF-H1-31) នៅអគារPH2 នេះមានតំឡើងទួរប៊ីន ៤ ដែលទួរប៊ីននីមួយៗអាចផលិត ថាមពលអគ្គិសនីបាន ៣,១ x ៣ = ៩,១ MW និងមួយទៀត កំលាំង ០,៨ MW សរុបថាមពលដែលផលិតណៅអគារនេះគឺ ១០,១ MW ។ អគារនេះធ្វើ ការផលិតថាមពលអគ្គិសនីក្នុង ១ ថ្ងៃ ២៤ ម៉ោងទាំងប្រាំង និងវស្សា (ករណីមានទឹកគ្រប់គ្រាន់ តាមផែនការ) ។

### ៤.៥.៥.៣ ទំនប់បណ្តោះអាសន្នខាងលើ (Upstream Cofferdam)

ទំនប់នេះនឹងសាងសង់នៅខាងលើទំនប់ទី២ (ទីតាំងសូមពិនិត្យមើលផែនទីលេខ៣) វាមានតួនាទីការពារទឹកកុំឱ្យហូរចូលទៅរំខានដល់ការសាងសង់ទំនប់ទី២ ទំនប់នេះមានទីរ៉ូខ្ពង់លើ ២៨.៥ម. និងទទឹងខ្នងលើ៧.៥ម.។ (មើល DWG No: KHP-TB-C-Plan-001 ) ។ ទំនប់នេះមានលក្ខណៈជាបណ្តោះអាសន្ន នៅពេលគេសាងសង់ទំនប់ទី២ រួចគេទំលាយវាចោលវិញ។

### ៤.៥.៥.៤ ទំនប់បណ្តោះអាសន្នខាងក្រោម (Downstream Cofferdam)

ទំនប់នេះនឹងសាងសង់នៅខាងក្រោមទំនប់ទី២ (ទីតាំងសូមពិនិត្យមើលផែនទីលេខ៣) ហើយវាមានតួនាទីការពារទឹកដូចទំនប់ខាងលើដែរ ។ ទំនប់នេះមានទីរ៉ូខ្ពង់លើ ២១ម និងទទឹងខ្នងលើ ៧.៥ម. (មើល DWG No: KHP-TB-C-Plan-001 ) ។ ទំនប់នេះមានលក្ខណៈជាបណ្តោះអាសន្ន នៅពេលគេសាងសង់ទំនប់ទី២ រួច គេទំលាយវាចោលវិញ។

## ៤.៥.៦ មធ្យោបាយ និងទព្វសំភារៈ-ឧបករណ៍សំរាប់សាងសង់គំរោង

ក្នុងការសាងសង់គំរោងវារីអគ្គិសនីនេះ តម្រូវការសំភារៈ ឧបករណ៍ និងទព្វសំភារៈដូចតទៅ :

**តារាង ៦ : សរុបចំនួនសំភារៈសំណង់សំរាប់សាងសង់គំរោងនេះ**

| បរិយាយ<br>Item | | ឯកតា<br>Unit | ចំនួន<br>Total Quantity |
|---|---|---|---|
| ស៊ីម៉ងត៍ | Cement | t | ១១០.០០០ |
| ខ្សាច់ | Sand | $m^3$ | ៨០០០.០០០ |
| ថ្មលាយបេតុង | Gravel | $m^3$ | ១២០០.០០០ |
| ដែកសរសៃ | Steel Bar | t | ១៦.០០០ |
| ពុម្ពដែក | Steel formwork | t | ៦.០០០ |
| ពុម្ពឈើ | Wooden Formwork | $m^3$ | ២.០០០ |
| ការលាយបេតុង | Admiture | t | ៣.៦០០ |
| ការបំផ្ទុះថ្ម | Exploisive | t | ១.៥០០ |
| ថ្ម | Stone | $m^3$ | ២.០០០.០០០ |

**តារាង ៧ : គំរូការមធ្យោបាយដឹកជញ្ជូនៈ**

| No. | ឧបករណ៍<br>Equipment | | ប្រភេទ<br>Model/Type | ឯកតា<br>Unit | ចំនួន<br>Qty. |
|---|---|---|---|---|---|
| A | ឧបករណ៍សំរាប់ធ្វើការជីកដី<br>Equipment for earth/rock works | | | | |
| 1 | ម៉ាស៊ីនខួង | Driller | CM351 | No. | 4 |
| 2 | ម៉ាស៊ីនចោះប្រហោងក្នុង | Down-hole driller | YQ-100B | No. | 10 |
| 3 | គ្រឿងចក្រកាយដី | Excavator | 1.87m3 CAT330D | No. | 1 |
| 4 | គ្រឿងចក្រកាយដី | Excavator | 1.2m3 CAT320 | No. | 2 |
| 5 | គ្រឿងចក្រសំរាប់ចូកចាក់ដី ឬថ្ម | Loader | CAT 966H | No. | 1 |
| 6 | គ្រឿងចក្រឈូស | Bulldozer | D7G | No. | 1 |
| 7 | ម៉ាស៊ីនចោះប្រហោងដោយដៃ | Hand-held driller | YT28 | No. | 70 |
| 8 | រថយន្តដឹកដី | Dump truck | 20t | No. | 30 |

| No. | ឧបករណ៍ Equipment | | ប្រភេទ Model/Type | ឯកតា Unit | ចំនួន Qty. |
|---|---|---|---|---|---|
| 9 | ម៉ាស៊ីនសំពាធខ្យល់ចល័ត | Mobile air compressor | RHP750 21.5m3 | No. | 2 |
| 10 | ម៉ាស៊ីនសំពាធខ្យល់ចល័ត | Mobile air compressor | VHP750 21.2 m3 | No. | 1 |
| 11 | រឡូកិនថ្នល់ | Vibration roller | 15t | No. | 1 |
| 12 | ម៉ាស៊ីនសំពាធខ្យល់ចល័ត | Mobile air compressor | VHP400 WCU 11.3m3 | No. | 2 |
| 13 | ម៉ាស៊ីនសំពាធខ្យល់ប្រើអគ្គិសនី | Electric air compressor | XAHS376E | No. | 8 |
| 14 | ម៉ាស៊ីនសំពាធខ្យល់ | Air compressor | XRHS836 | No. | 2 |
| 15 | ម៉ាស៊ីនសំពាធខ្យល់ | Air compressor | XAHS836 | No. | 5 |
| 16 | ម៉ាស៊ីនសំពាធខ្យល់ | Air compressor | XATS156 | No. | 2 |
| 17 | រថយន្តដឹករំសេវ | Explosive truck | HYJ5121XQY | No. | 2 |
| 18 | គ្រឿងចក្រសំរាប់ចូកចាក់ដី ឬថ្ម | Loader | (3CX) | No. | 1 |
| 19 | គ្រឿងចក្រសំរាប់ចូកចាក់ដី ឬថ្ម | Loader | CLG 856 | No. | 1 |
| B | **ឧបករណ៍សំរាប់ធ្វើការចាក់បេតុង** | Equipment for concrete works | | | |
| 1 | ម៉ាស៊ីនជំនួយសំរាប់លាយបេតុង | Batching plant | HL240-2S3000 | Set | 1 |
| 2 | ម៉ាស៊ីនជំនួយសំរាប់លាយបេតុង | Batching plant | HL320-2S4500 | Set | 1 |
| 3 | ប្រព័ន្ធកិនថ្ម និងចាក់បង្គរ | *Aggregate production system* | 1500t/h | Set | 1 |
| 4 | ឧបករណ៍លាយបេតុង | Forcing type mixer | Z50 | No. | 2 |
| 5 | ដងស្ទូច | Tower crane | TC7052 | No. | 1 |
| 6 | រថយន្តស្ទូច | Truck crane | 80t | No. | 1 |
| 7 | រថយន្តស្ទូច | Truck crane | 50t | No. | 1 |
| 8 | រថយន្តស្ទូច | Truck crane | 40t | No. | 1 |
| 9 | រថយន្តស្ទូច | Truck crane | QY16H-3 | No. | 3 |
| 10 | រថយន្តលាយស៊ីម៉ង់ត៍ | Concrete mixer truck | 6m3 | No. | 4 |
| 11 | ម៉ាស៊ីនបូម/បាញ់ស៊ីម៉ង់ត៍ | Concrete pump | HBT60.16.110SB | No. | 3 |
| 12 | រថយន្តស្ទូច | Truck crane | ZZ1121G5311W | No. | 3 |
| 13 | រថយន្តដឹកដី (45t) | Dump truck (45t) | ZZ3251M4261W/M | No. | 10 |
| 14 | រថយន្តធន់ធ្ងន់ (20t) | Heavy duty truck(20t) | ZZ1251M4841W/L | No. | 3 |
| 15 | រថយន្តធន់ធ្ងន់ (6t) | Heavy duty truck(6t) | ZZ1141H5315W | No. | 1 |
| 16 | ឧបករណ៍ញ័រ | Vibrator | ZDN100 | No. | 80 |
| 17 | ឧបករណ៍ញ័រ | Vibrator | ZN50 | No. | 20 |
| C | **ឧបករណ៍ផ្សេងៗ** | Other equipment | | | |
| 1 | ម៉ាស៊ីនភ្លើងប្រើម៉ាស៊ូត | Diesel generator | VPC450 | No. | 4 |
| 2 | ម៉ាស៊ីនភ្លើងប្រើម៉ាស៊ូត | Diesel generator | Denyo 25 | No. | 1 |
| 3 | ឧបករណ៍/សម្ភារៈសំរាប់ការងារធ្វើឈើ | Carpentry equipment | | Set | 1 |
| 4 | ឧបករណ៍/សម្ភារៈសំរាប់ការងារដែក | Steel processing equipment | | Set | 1 |

| No. | ឧបករណ៍ Equipment | | ប្រភេទ Model/Type | ឯកតា Unit | ចំនួន Qty. |
|---|---|---|---|---|---|
| 5 | សម្ភារៈអគ្គិសនី | Electrical equipment | | Set | 1 |
| 6 | ម៉ាស៊ីនបូមទឹក | Water pump | WB30XT | No. | 1 |
| 7 | ម៉ាស៊ីនភ្លើងប្រើម៉ាស៊ូត | Diesel generator | DC-3 | No. | 1 |
| 8 | ម៉ាស៊ីនផ្សារ | Welding machine | ZX5-500K | No. | 2 |
| 9 | ម៉ាស៊ីនបូមទឹកសម្ពាធខ្ពស់ | High pressure water pump | | No. | 2 |
| 10 | ម៉ាស៊ីនបូមទឹក | Water pump | | No. | 5 |
| 11 | ឧបករណ៍បុកគ្រឹះ | Earth rammer | | No. | 1 |
| 12 | ម៉ាស៊ីនផ្សារ | Welding machine | | No. | 2 |
| 13 | ម៉ាស៊ីនសំលៀង | Sharpening machine | | No. | 1 |
| 14 | ម៉ាស៊ីនលាយបាយអរ | Mortar mixer | | No. | 4 |
| 15 | ម៉ាស៊ីនភ្លើង | Generator | | No. | 2 |
| 16 | រថយន្តធន់ធ្ងន់ | Truck | | No. | 2 |
| 17 | ឧបករណ៍ស្ទង់ | Survey instrument | | Set | 1 |
| 18 | ម៉ាស៊ីនវង្វាស់តូប៉ូ | Theodolite | TC402 | No. | 1 |
| 19 | ឧបករណ៍វាស់បញ្ឈរ | Stand measure apparatus | TCR402 | No. | 1 |
| 20 | រថយន្តស៊ីទែនទឹក | Tank truck | JG5163GJY | No. | 2 |
| 21 | រថយន្តបាញ់ទឹក | Sprinkling truck | JG5142GSS | No. | 2 |
| 22 | រថយន្តស្ទូច | Truck crane | 8t | No. | 1 |
| 23 | រថយន្តស្ទូច | Truck crane | 80t | No. | 1 |
| 24 | រថយន្តស្ទូច | Truck crane | 50t | No. | 1 |
| 25 | រថយន្តស្ទូច | Truck crane | 40t | No. | 1 |
| 26 | គ្រឿងចក្រសំរាប់លើកដាក់ | Fork lift truck | 2t | No. | 1 |
| 27 | គ្រឿងចក្រសំរាប់លើកដាក់ | Fork lift truck | CPCD50H-F05W | No. | 1 |
| 28 | កន្ទុយសណ្ដោង | Flat-bed trailer | 60t | No. | 1 |
| 29 | ជញ្ជីងថ្លឹងឡាន | Weighbridge | SCS-80 | No. | 2 |
| 30 | រថយន្តបាញ់ទឹក | Sprinkling truck | ZZ1251M4441W/L | No. | 2 |
| 31 | គ្រឿងចក្រប្រើឥន្ធនៈ | Fuel truck | ZZ1251M4211W/L | No. | 2 |
| 32 | ឡានពេទ្យ | Ambulance | SH5492XJH | No. | 1 |
| 33 | គ្រឿងចក្រសំរាប់ថែទាំផ្លូវ | Maintenance vehicle | | No. | 2 |
| 34 | រថយន្តដឹកសំភារៈ ឬគ្រឿងផ្ទុះ | Explosive truck | 6t | No. | 2 |
| 35 | គ្រឿងចក្រសំរាប់ចូកចាក់ដី ឬថ្ម | Loader | JCB-3CX | No. | 1 |
| 36 | គ្រឿងចក្រសំរាប់ថែទាំផ្លូវ | Maintenance vehicle | ZZ5121XXYG4751W | No. | 2 |
| 37 | រថយន្តពន្លត់អគ្គិភ័យ | Fire fighting truck | LLX516OGXFPF40X | No. | 1 |

## ៤.៥.៧ ខ្សែបញ្ជូនចរន្តដែលមានតង់ស្យុងខ្ពស់ ២៣០គីឡូវ៉ុល និងតង់ស្យុងមធ្យម ២២គីឡូវ៉ុល (High Voltage Transmission Line (230 kV) and Midium Voltage Transmission Line 22 kV

ក្រុមហ៊ុននឹងសាងសង់វាលសំរាប់ដាក់ត្រង់ស្វ័រម៉ាទ័រដែលមានតង់ស្យុងខ្ពស់ ២៣០គីឡូវ៉ុល ស្ថិតនៅក្បែរអគារថាមពលទី ១ និងខ្សែចំលងសៀគ្វីឌុបតង់ស្យុងខ្ពស់ ២៣០ គីឡូវ៉ុលដែរប្រវែងសរុប ១១,០៥ គ.ម ដោយភ្ជាប់ទៅអនុស្ថានីយន៏អគ្គិសនីកំពត (របស់អគ្គិសនីកម្ពុជា) ។ ដោយឡែកឯអគ្គិសនីកម្ពុជា នឹងតប្រព័ន្ធខ្សែចំលងចរន្តអគ្គិសនី តង់ស្យុងខ្ពស់ ចែកចាយទៅទីក្រុងភ្នំពេញ និងទីក្រុង ព្រះសីហនុដោយខ្លួនឯង ។ ប្រពន្ធ័ខ្សែបញ្ជូនចរន្តតង់ស្យុងខ្ពស់ ២៣០ គីឡូវ៉ុលនេះ មាន ៣៤ បង្គោល ។

ចំពោះបង្គោលខ្សែចម្លងទាំងនេះមានកំពស់ទៅតាមរយៈកំពស់ដី គឺចាប់ពីប្រមាណ ៣០ម ទៅ ៦៥ ម ដែលយោងទៅតាមស្ថានភាព ដីទំនាប ឬ ភ្នំ ចំងាយប្រឡោះពីបង្គោលមួយទៅបង្គោលមួយគឺ ១២០ ទៅ ៤៤០ ម ការសាងសង់បង្គោលទាំងនោះតំរូវការផ្ទៃដីសំរាប់បង្គោល១គឺទំហំ ៤០០ម² (២០ម x ២០ម) ។ ក្រុមហ៊ុនក៏ត្រូវការដី បណ្តោះអាសន្នសំរាប់ដាក់ សំភារៈសំណង់ និងផ្លូវចេញចូលសំរាប់ការសាងសង់ផងដែរ ។

ដើម្បីធានាសុវត្ថិភាព និងនិរន្តរភាពក្នុងការបញ្ជូនចរន្តដល់អ្នកប្រើប្រាស់នៅតាមបណ្តាខេត្ត និងក្រុងនានាដូចជា ខេត្តតាកែវ និងរាជធានី ភ្នំពេញជាដើម (តាមផែនការមេនៃខ្សែបញ្ជូនដែលមានតង់ស្យុងខ្ពស់២៣០គីឡូវ៉ុល របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល) គន្លងខ្សែចម្លងនេះនឹងត្រូវគណនាដោយគិតពីសុវត្ថិភាពកុំឱ្យ គ្រោះថ្នាក់ដល់មនុស្ស សត្វ គឺមានទំហំ ១៥ ម ចេញពីអក្ស័គន្លង (សរុប ៣០ម ) និងត្រូវសំអាតដើមឈើដូចរូបទី ៣ខាងក្រោម (កំពស់មិនលើសពី ៣ ម) ។

**សំគាល់:** នៅក្រោមតំបន់ខ្សែបញ្ជូលចរន្តតង់ស្យុងខ្ពស់នេះ (ទទឹង ៣០ម) ដើមឈើ ឬ ដំណាំ ដែលមានកំពស់ធំជាង ៣ ម មិនត្រូវបានអនុញ្ញាតឱ្យមានក្នុងតំបន់នេះទេ ។ ចំពោះលំនៅដ្ឋាន ឬការរស់នៅរបស់ប្រជាពលរដ្ឋជាប្រចាំនៅក្នុងតំបន់នេះក៏ត្រូវបានហាមឃាត់ផងដែរមើលរូប៣ខាងក្រោម ។ យោងទៅតាមការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមនេះបានបង្ហាញថាមានលំនៅដ្ឋាន និង ដីស្រែចំការរបស់ប្រជាពលរដ្ឋរស់នៅក្រោមតំបន់ខ្សែបញ្ជូនចរន្តនេះ ផងដែរ (សិក្សាខែតុលា ដល់ ធ្នូ ឆ្នាំ២០១០) ។




**ការសំអាតគន្លងខ្សែ**

បន្ថែមពីនេះក្រុមហ៊ុននិង តំលើងត្រង់ស្វ័រម៉ាទ័រដែលមានតង់ស្យុងមធ្យម ២២ គីឡូវ៉ុល ក្បែរ អគារថាមពលទី២ ហើយភ្ជាប់ទៅបណ្តាញអគ្គិសនីខេត្តកំពត ត្រង់ស្ថានីយន៏បូមទឹកឆៅ ខេត្តកំពត ដែលមានប្រវែង ១,៩គម ។




**បង្គោលខ្សែតង់ស្យុងខ្ពស់ ២៣០ គ.វ**

## ៤.៦ ផែនការ និង សកម្មភាពការងារសាងសង់របស់គំរោង (CONSTRUCTION PLAN AND PROJECT ACTIVITY)

វារីអគ្គិសនីកំចាយ ស្ថិតនៅក្នុងស្រុកទឹកឈូ ខេត្តកំពត របស់ក្រុមហ៊ុន Kamchay Sinohydro Hydroelectric Co,Ltd. ដែលបាន ចុះហត្ថលេខាបញ្ជាក់ យល់ព្រមដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានផែនការ និង សកម្មភាពសាងសង់ដូចតទៅ :

### ៤.៦.១ ការរៀបចំគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធរបស់គំរោង (Infrastructure Management System of The Project)

#### ៤.៦.១.១ ផែនការ និង តារាងពេលវេលានៃការសាងសង់ (Kamchay Project Development Schedule)

**ផែនការចំបងរបស់គំរោង** (Project Milestones)

ក្នុងផែនការចំបងក្រុមហ៊ុនបានបែងចែកជា ២២ សកម្មភាពសំរាប់ការធ្វើវារីអគ្គិសនីនេះក្នុងរយៈពេល ៤ឆ្នាំ មានដូចតទៅ : (មើលក្នុងក្រាហ្វិកបែងចែកពេលវេលាសាងសង់ខាងក្រោម)

១- ការចុះកិច្ចសន្យារបស់គំរោង (Project Agreements) ក្នុងកំឡុងពេល ២ខែ ចាប់ផ្តើមពីដើមខែទី ១ ។

២- ប្រសិទ្ធិភាពកាលបរិច្ឆេទនៃការអនុវត្តគំរោងជាផ្លូវការ (Effectiveness Date) ក្នុងកំឡុងពេល ១ខែ ចាប់ផ្តើមពីដើមខែទី ៣ ។

៣- ការរៀបចំរបាយការណ៍ IESIA និងការយល់ព្រមលើរបាយការណ៍នេះ (Conducting IESIA and Approval) ក្នុងកំឡុងពេល ១ខែ ចាប់ផ្តើមពីដើមខែទី ៣ ។

៤- ការផ្តល់វិញ្ញាបនប័ត្រក្នុងការសាងសង់គំរោង (Construction Licenses) ក្នុងកំឡុងពេល ១ខែ ចាប់ផ្តើមពីដើមខែទី ៣ ។

៥- ការយល់ព្រមក្នុងការនាំចូលសំភារះ និងគ្រឿងបរិក្ខារសំរាប់សាងសង់គំរោង (Procurement Approval) ក្នុងកំឡុងពេល ១ខែ ចាប់ផ្តើមពីដើមខែទី ៣ ។

៦- ចាប់ផ្តើមការសាងសង់ (Construction Commence) ក្នុងកំឡុងពេល ១ខែ ចាប់ផ្តើមពីដើមខែទី ៣ គឺខែមេសា ឆ្នាំ២០០៧ ។

៧- ការចុះបញ្ជី (Registration) ក្នុងកំឡុងពេល ១ខែ ចាប់ផ្តើមពីដើមខែទី ៤ ។

៨- ការអនុញ្ញាតឱ្យវិនិយោគទុនជាផ្លូវការ (Investment Approval) ក្នុងកំឡុងពេល៧ខែ ចាប់ផ្តើមពីដើមខែទី៥ ។

៩- ការបិទបញ្ជីហិរញ្ញវត្ថុរបស់គំរោង (Project Finance Closing) ក្នុងកំឡុងពេល៥ខែ ចាប់ផ្តើមពីដើមខែទី១៣

១០- ការចាប់ផ្តើមនៃការងារសាងសង់សំខាន់ៗ (Commencement of Main Construction Work) ក្នុងកំឡុងពេល ៥ខែ ចាប់ផ្តើមពីដើមខែ ទី ១៣ ។

១១- ការចាប់ផ្តើមនៃការសាងសង់សំណង់ច្រកទឹកចូលនិងសំណង់បង្វែរទឹក (Commencement to Construct Power Intake & Conduit) ក្នុងកំឡុងពេល ៣ខែ ចាប់ផ្តើមពីពាក់កណ្តាលខែ ទី ១៧ ។

១២- ការបិទព្រែកទឹកឈូទាំងស្រុង (Complete River Closure) ក្នុងកំឡុងពេល ៣ ខែ ចាប់ផ្តើមពីពាក់កណ្តាល ខែ ទី ២០ ។

១៣- ការចាប់ផ្តើមសាងសង់ទំនប់បេតុង (Commencement Dam Concrete Placement) ក្នុងកំឡុងពេល ១២.៥ខែ ចាប់ផ្តើមពីពាក់កណ្តាលខែ ទី ២៣.៥ ។

១៤- ការបិទទ្វារទឹករបស់បំពង់បង្វែរទឹក (Close Diversion Tunnel Gate) ក្នុងកំឡុងពេល ៦ខែ ចាប់ផ្តើមពីដើមខែ ទី ៣៦ ។

១៥- ការអនុញ្ញាតក្នុងការប្រើប្រាស់ទឹក (Water Utilization Authorization) ក្នុងកំឡុងពេល ៦ខែ ចាប់ផ្តើមពីដើមខែ ទី ៣៦ ។

១៦- ការផ្តល់ វិញ្ញាបនប័ត្រក្នុងការបង្កើតថាមពលអគ្គិសនី (Generation Licenses) ក្នុងកំឡុងពេល ៧ខែ ចាប់ផ្តើម ពីដើមខែ ទី ៣២ ។

១៧- រោងចក្រផលិតថាមពលទី ១ ដំណើរការ (Unit # 1 in Service) ក្នុងកំឡុងពេល ៣ ខែ ចាប់ផ្តើម ពីដើមខែ ទី ៤៩ ។

១៨- រោងចក្រផលិតថាមពលទី ២ ដំណើរការ (Unit # 2 in Service) ក្នុងកំឡុងពេល ១.៥ ខែ ចាប់ផ្តើម ពីដើមខែ ទី ៥២ ។

១៩- ទំនប់បង្វែរសំរាប់លៃតំរូវចរន្តទឹកនៅខាងក្រោមដំណើរការ (Re-Regulation Weir Generates in Service) ក្នុងកំឡុងពេល ១.៥ ខែ ចាប់ផ្តើម ពីដើមខែ ទី ៥២ ។

២០- ការសាងសង់ចប់ជាស្ថាពរនៃទំនប់ទី ១ (Complete RRC Dam Placement) ក្នុងកំឡុងពេល ១.៥ ខែ ចាប់ផ្តើម ពីពាក់កណ្តាលខែ ទី ៥៣ ។

២១- រោងចក្រផលិតថាមពលទី ៣ ដំណើរការ (Unit # 3 in Service) ក្នុងកំឡុងពេល ១.៥ ខែ ចាប់ផ្តើម ពីដើមខែ ទី ៥៥ ។

២២- ការសាងសង់គំរោងត្រូវបានបញ្ចប់ជាស្ថាពរ (Complete Project Construction) បញ្ចប់ការសាងសង់នៅពាក់កណ្តាលខែទី ៦០ គឺនៅខែមេសា ឆ្នាំ២០១២ ។

## តារាង ៨ : ពេលវេលានៃការសាងសង់ (Project Development Schedule)

ក្រុមហ៊ុនរៀបចំផែនការអនុវត្តសាងសង់រយៈពេល ៤ ឆ្នាំគឺ (មើលតារាង ៨ ពេលវេលានៃការសាងសង់ខាងក្រោម):

| ល.រ | សកម្មភាព | | មុនសាងសង់ | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | ប្រតិបត្តិរយៈ៤០ឆ្នាំ |
|---|---|---|---|---|---|---|---|---|
| ០ | ការរៀបចំ និងគ្រប់គ្រង | | | | | | | |
| ១ | វិធានការណ៍កាត់បន្ថយ ហេតុប៉ះពាល់សំរាប់ការសាងសង់ | Mitigation Measure for Construction Related Impacts | | | | | | |
| ១.១ | ការសំអាតរុក្ខជាតិ និង ការងារដីនៅក្នុងការដ្ឋាន (ការសំអាតរុក្ខជាតិ, ការត្រួតពិនិត្យការហូរច្រោះ និងចាក់បង្ករ) | Disturbance to Vegetation & Land in the Vicinity of the Construction Areas (Vegetation Clearing, Erosion and sedimentation control) | | | | | | |
| ១.២ | ការចោលសំណល់ស្មុយ | Spoil Disposal | | | | | | |
| ១.៣ | គ្រប់គ្រងសំណល់ (ការគ្រប់គ្រងសំណល់រាវ សំណល់រឹង និង សំណល់គីមី) | Waste management (Wastewater, Solid Waste and Chemical Waste Management) | | | | | | |
| ១.៤ | គុណភាពខ្យល់ និងសំលេង | Air Quality and noise | | | | | | |
| ១.៥ | ការបង្កើនគុណភាពទឹកនៅក្នុងអាងទី២ ដោយបន្ថយជីវៈម៉ាសនៅក្នុងទឹក (ការសំអាតអាង) | Water Quality Improvement by Reduction Biomass in Small Reservoir (Reservoir clearance) | | | | | | |
| ១.៦ | ការស្តារ និងត្រួតពិនិត្យឡើងវិញ | Rehabilitation | | | | | | |

| ល.រ | សកម្មភាព | | មុនសាងសង់ | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | ប្រតិបត្តិការរោង៤០ឆ្នាំ |
|---|---|---|---|---|---|---|---|---|
| ១.៧ | ការដាំដើមឈើ (ដាំរុក្ខជាតិ និងព្រៃឈើឡើងវិញ) | Plantation Forestry (Re-vegetation and reforestation) | | | | | | |
| ១.៨ | ការអភិរក្សតំបន់ជីវសាស្ត្រ | Biological land conservation | | | | | | |
| ១.៩ | វិធានការណ៍គ្រប់គ្រងក្នុងការដឹកជញ្ជូន សំរាប់ការសាងសង់ផ្លូវ និងជំរុំកម្មករ | Management measures for transmission, Road and Camp construction | | | | | | |
| ២ | កម្មវិធីត្រួតពិនិត្យ | Monitoring Program | | | | | | |
| ២.១ | ការតាមដានត្រួតពិនិត្យមើលឧតុនិយម | Meteorological monitoring | | | | | | |
| ២.២ | គុណភាពទឹកលើដី និងការហូរច្រោះ | Surface water quality and erosion | | | | | | |
| ២.៣ | ទឹកស្អាត | Village drinking water | | | | | | |
| ២.៤ | ជីវសាស្ត្រនៅក្នុងទឹក និងសត្វព្រៃ | Aquatic biology and wildlife | | | | | | |
| ២.៥ | ផ្ទៃរងទឹកភ្លៀង និងការប្រើប្រាស់ដី | Catchment and land use | | | | | | |
| ២.៦ | ការបង្កើនជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ | Livelihood improvement | | | | | | |

## ៤.៦.២ ខ្សែសង្វាក់ផលិតកម្មចំពោះការសាងសង់វារីអគ្គិសនី

គំនូសបំព្រួញនៃខ្សែសង្វាក់ផលិតកម្ម របស់គំរោងវិនិយោគទុនលើវារីអគ្គិសនីកំចាយ ខេត្តកំពត របស់ក្រុមហ៊ុន Kamchay Sinohydro Hydroelectric Co,Ltd.




## ៤.៦.៣ កំលាំងពលកម្ម (Labors)

### ក. ពលកម្មក្នុងស្រុក (Local Labors)

ក្រុមហ៊ុនមានគំរោងផែនការជ្រើសរើសបុគ្គលិក-កម្មករ ការជ្រើសរើសនេះក្រុមហ៊ុនផ្តល់អាទិភាពចំពោះប្រជាជនដែលរស់នៅក្បែរតំបន់គំរោង ។

### ១- កំឡុងពេលសាងសង់

ផែនការរបស់ក្រុមហ៊ុនក្នុងការជ្រើសរើសបុគ្គលិក-កម្មករក្នុងពេលសាងសង់រយៈពេល៤ឆ្នាំមានរហូតទៅដល់២២៣៦ នាក់ ជាប្រជាពលរដ្ឋជុំវិញតំបន់គំរោង និង បុគ្គលិក-កម្មករចិនចំនួន ២៣៦ នាក់ ។

| 1. Construction phase | | Khmer | Chinese |
|---|---|---|---|
| | | Unit (person) | |
| | Manager | | 6 |
| | Staff | | 200 |
| | Admin | | 30 |
| | Workers | 2000 | 36 |
| | other | | |
| | | | |
| | Total | 2000 | 236 |

**២- កំឡុងពេលប្រតិបិត្ត និង ថែទាំ**

| 2. O&M | | Khmer: | Chinese: |
|---|---|---|---|
| | Managing supervisor, administration staff | 1 | 4 |
| | Water and electric engineer | 2 | 2 |
| | Operational staff | 12 | 24 |
| | Operation and Maintenance Staff | 6 | 8 |
| | Information service staff | 2 | 3 |
| | other | 23 | 41 |

### ៤.៦.៤ ការប៉ាន់ប្រមាណតំលៃនៃគំរោង Project Cost Estimate

គំរោងវារីអគ្គិសនីស្ទឹងកំចាយនេះ អាចមានលទ្ធភាពផលិតថាមពលអគ្គិសនីបានដល់ទៅ ១៩៤,១ MW ហើយត្រូវការរយៈពេលសាងសង់ ៤ឆ្នាំ (ដោយចាប់ផ្តើមសាងសង់ពីខែមិថុនា ឆ្នាំ២០០៧ និងបញ្ចប់នៅខែមិថុនាឆ្នាំ២០១២) ។ គំរោងនេះមានតំលៃវិនិយោគសរុប **៣៣០** លាន (ពីររយប៉ែតសិបលានដុល្លាអាមេរិច) ដុល្លារអាមេរិក ។

### ៤.៦.៥ ផែនការគ្រប់គ្រងសំណល់គ្រប់ប្រភេទ (Waste Management Plan)

- ក្រុមហ៊ុននឹងរៀបចំរណ្តៅសំរាប់សំណល់រឹងផ្សេងៗ និងសំណល់ផ្ទះបាយ ដែលមានទីតាំងស្ថិតនៅឆ្ងាយពីប្រភពទឹក និងស្ថិតនៅក្រោមខ្យល់ ។ ជាងនេះទៅទៀត ក្រុមហ៊ុននឹងមានបច្ចេកទេសក្នុងការគ្រប់គ្រង នៅទីតាំងចាក់សំរាមដោយមានរថយន្តសំរាប់ចាក់ដី និង បង្ហាប់ពីលើសំណល់ជារៀងរាល់សប្តាហ៍ដើម្បីការពារការក្លិន និងចាក់ដីជុំវិញរណ្តៅដើម្បីការពាការហូរច្រោះទឹកទៅបំពុលតំបន់ក្បែរៗនោះ ព្រមទាំងមានរបងការពារសត្វកុំឱ្យចូលក្នុងរណ្តៅទៀតផង ។ ចំពោះកាកសំណល់រឹងទាំងនេះ (សំរាមផ្ទះបាយ និងការិយាល័យ) ក្រុមហ៊ុននឹងមានអ្នកទទួលខុសត្រូវ ឬ ជួលឱ្យក្រុមហ៊ុនឯកជន ជាអ្នកគ្រប់គ្រង ។ (មានលម្អិតបន្ថែម ឬអាចមានការផ្លាស់ប្តូរនៅពេលគំរោងចាប់ផ្តើម)
- រីឯសំណល់រាវវិញ ក្រុមហ៊ុននឹងរៀបចំប្រពន្ធ័អាងសិបទិកទំនើបដែលទទួលយកទឹកកខ្វក់ពីផ្ទះបាយ បង្គន់អនាម័យ និងកន្លែងត្រង់ស្វូរ ។ (មានលម្អិតនៅពេលគំរោងចាប់ផ្តើម)

- **ប្រពន្ធ័ការពារអគ្គីភ័យ** Fire fighting system:

- មានប្រពន្ធ័ប្រើប្រាស់ទឹក ដោយតំឡើងវ៉ាន សំរាប់អគ្គីភ័យនៅតាមជាន់នីមួយៗរបស់អគារ ។
- បំពាក់ប្រពន្ធ័បំពង់ពន្លត់អគ្គីភ័យ(បំពង់ជ័រ២ ឬ ម្សៅពន្លត់អគ្គីភ័យស្ងួតចំនួន៦០, ប្រភេទទាញបើកបាញ់ ៣៥ គក្រ. ចំនួន ៤, ពូថៅ ៤, រណ្តៅខ្សាច់ ១, ប៉ែល ១០ និង អាគុយ សំរាប់ បំភ្លឺ ចំនួន ១៥) ។
- បំពង់ពន្លត់អគ្គិសភ័យ (ធិរ ខេតិឆងិសហរេ) នឹងត្រូវបំពាក់នៅគ្រប់បន្ទប់ស្នាក់នៅរបស់បុគ្គលិក កម្មករ, ការិយាល័យ, និងតាមអគារនានារបស់គំរោង ។
- ក្រុមហ៊ុននឹងរៀបចំប្រព័ន្ធទឹកអគ្គិសភ័យ ( Fire Hydrant) នៅតាមទីតាំងអគារ, កន្លែងត្រង់ស្វូរ, ការិយាល័យ, កន្លែងស្នាក់នៅរបស់បុគ្គលិក កម្មករ ។
- បំពាក់ប្រពន្ធ័ផ្តល់ដំណឹងស្វ័យប្រវត្តិ ចំនួន ៤ ព្រមទាំងមានរថយន្តពន្លត់អគ្គិភ័យផងដែរ ។ (មានលំអិតនៅពេលគំរោងចាប់ផ្តើម)